**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# របាយការណ៍លទ្ធផល
# ស្តីពី
# ការរៀបចំប្រារព្ធទិវាជាតិអំណានលើកទី៩ ១១ មីនា ២០២៤
# ក្រោមប្រធានបទ
# «អំណានជាមូលដ្ឋានគ្រឹះសម្រាប់ទាំងអស់គ្នាក្នុងជីវិត»






**នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា**
**១១ មីនា ២០២៤**

# មាតិកា

**ខ្លឹមសារ** **ទំព័រ**

***មាតិកា*** ....................................................................................... ១

***សេចក្តីផ្តើម*** ................................................................................... ៣

***I.គោលបំណង*** ................................................................................. ៣

***II.យុទ្ធវិធី*** ....................................................................................... ៤

***III.សកម្មភាព និងលទ្ធផលនៃការរៀបចំទិវាជាតិអំណានលើកទី៩*** ..................... ៤

១.ការត្រៀមរៀបចំប្រារព្ធពិធីទិវាជាតិអំណានលើកទី៩ ........................................ ៤

ក.កិច្ចប្រជុំពិភាក្សា ត្រៀមរៀបចំប្រារព្ធពិធីទិវាជាតិអំណានលើកទី៩ ១១ មីនា ២០២៤ ...... ៤

ខ. ការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងលិខិតរដ្ឋបាលផ្សេងៗ ............................... ៦

២.ការប្រឡងប្រជែងជ្រើសរើសបេក្ខជនជ័យលាភី ................................................ ៦

ក. ការប្រឡងប្រជែងជ្រើសរើសបេក្ខជនជ័យលាភីថ្នាក់ក្រោមជាតិ ............................ ៦

ខ. ការប្រឡងប្រជែងជ្រើសរើសបេក្ខជនជ័យលាភីថ្នាក់ជាតិ .................................... ៨

គ. ការប្រកាសលទ្ធផលប្រឡងប្រជែងជ្រើសរើសបេក្ខជនជ័យលាភីថ្នាក់ជាតិ ................. ១៤

៣.ការតាំងពិព័រណ៍សៀវភៅ អបអរសាទរទិវាជាតិអំណានលើកទី៩ ............................ ១៧

៤.ការប្រារព្ធទិវាជាតិអំណានលើកទី៩ ១១ មីនា ២០២៤ ........................................ ១៨

ក. របាយការណ៍វឌ្ឍនភាពស្តីពី«ការរៀបចំទិវាជាតិអំណានចាប់ពីឆ្នាំ២០១៦ដល់ឆ្នាំ២០២៣»១៨

ខ. សុន្ទរកថាបើកការប្រារព្ធពិធីទិវាជាតិអំណានលើកទី៩ ១១ មីនា ២០២៤.................. ១៩

គ. ពិធីប្រគល់ពានរង្វាន់ជ័យលាភី.......................................................................... ១៩

ឃ. ការឧបត្ថម្ភ....................................................................................................... ២២

ង.បាឋកថាស្រាវជ្រាវស្តីពី«តួនាទីអំណានក្នុងការលើកកម្ពស់គុណភាពអប់រំនិងសាលារៀនគំរូ»២២

ច. កម្មវិធីពេលរសៀល ............................................................................................ ២៣

ឆ. វេទិកាពិភាក្សាតុមូល .......................................................................................... ២៣

***IV.សេចក្តីសន្និដ្ឋាន*** ........................................................................................ ៣១

# ឧបសម្ព័ន្ធ


ឧបសម្ព័ន្ធទី១ សេចក្តីសម្រេច ស្តីពី ការបង្កើតគណៈកម្មការគ្រប់គ្រង និងដឹកនាំរៀបចំ ទិវាជាតិអំណានលើកទី៩ ១១ មីនា ២០២៤...................................... i

ឧបសម្ព័ន្ធទី២ សេចក្តីណែនាំ ស្តីពី ការប្រារព្ធទិវាជាតិអំណាន ......................................vii

ឧបសម្ព័ន្ធទី៣ សេចក្តីណែនាំ ស្តីពី ការប្រឡងប្រជែងអាន ស្មូតកំណាព្យ និងតែងនិពន្ធ អបអរសាទរទិវាជាតិអំណាន ១១ មីនា...............................................viii

ឧបសម្ព័ន្ធទី៤ សេចក្តីប្រកាសព័ត៌មានស្តីពី ការប្រឡងប្រជែងបកស្រាយប្រធានបទ «តួនាទីព្រះពុទ្ធសាសនាក្នុងការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌.xiv

ឧបសម្ព័ន្ធទី៥ បញ្ជីឈ្មោះបេក្ខជនចូលរួមប្រឡងប្រជែងផ្នែកអានអត្ថបទ .......................xv

ឧបសម្ព័ន្ធទី៦ បញ្ជីឈ្មោះបេក្ខជនចូលរួមប្រឡងប្រជែងផ្នែកស្មូតកំណាព្យ .....................xvi

ឧបសម្ព័ន្ធទី៧ បញ្ជីឈ្មោះបេក្ខជនចូលរួមប្រឡងប្រជែងផ្នែកតែងនិពន្ធ .........................xvii

ឧបសម្ព័ន្ធទី៨ បញ្ជីឈ្មោះបេក្ខជនចូលរួមប្រឡងប្រជែងផ្នែកបកស្រាយប្រធានបទ ..........xviii

ឧបសម្ព័ន្ធទី៩ សេចក្តីប្រកាសព័ត៌មានស្តីពី ការប្រារព្ធទិវាជាតិអំណានលើកទី៩ ១១ មីនា ២០២៤.......................................................................................xxii

ឧបសម្ព័ន្ធទី១០ បញ្ជីសមាសភាពអញ្ជើញចូលរួមប្រារព្ធទិវាជាតិអំណាន ..........................xxiii

ឧបសម្ព័ន្ធទី១១ កម្មវិធីប្រឡងប្រជែងអាន ស្មូតកំណាព្យ និងតែងនិពន្ធ ...........................xxvii

ឧបសម្ព័ន្ធទី១២ កម្មវិធីប្រារព្ធទិវាជាតិអំណានលើកទី៩ ................................................xxix

ឧបសម្ព័ន្ធទី១៣ កម្មវិធីសម្ពោធស្តង់ពិព័រណ៍សៀវភៅ ...................................................xxxi

ឧបសម្ព័ន្ធទី១៤ តារាងពិន្ទុបេក្ខជនចូលរួមប្រឡងប្រជែងអាន ស្មូតកំណាព្យ និងតែងនិពន្ធ xxxii

ឧបសម្ព័ន្ធទី១៥ បញ្ជីឈ្មោះបេក្ខជនជ័យលាភីថ្នាក់ជាតិ ................................................xxxv

ឧបសម្ព័ន្ធទី១៦ បញ្ជីឈ្មោះស្តង់ពិព័រណ៍ ................................................................xxxvii

## **សេចក្តីផ្តើម**

យោងអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាស្តីពី**ទិវាជាតិអំណាន** ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំប្រារព្ធទិវាជាតិអំណានបានចំនួន៨លើករួចមកហើយចាប់ពីឆ្នាំ២០១៦មក។ ការរៀបចំទិវាជាតិអំណានជារៀងរាល់ឆ្នាំមានកម្មវិធីផ្សេងៗដូចជា ការប្រឡងប្រជែងអាន ស្ធូតកំណាព្យ និងតែងនិពន្ធ សម្រាប់ទទួល «**ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន**» ការរៀបចំពិព័រណ៍សៀវភៅ ការប្រឡងប្រជែងផ្នែកបកស្រាយប្រធានបទ ការធ្វើបាឋកថាស្រាវជ្រាវ និងវេទិកាពិភាក្សាតុមូលដោយវាគ្មិនល្បីៗ។

ដោយឡែកឆ្នាំ២០២៤នេះក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងព័ត៌មាន បានរៀបចំទិវាជាតិអំណានលើកទី៩ ក្រោមប្រធានបទ « **អំណានជាមូលដ្ឋានគ្រឹះសម្រាប់ទាំងអស់គ្នាក្នុងជីវិត**» នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងមានការផ្សាយបន្តផ្ទាល់តាមទំព័របណ្តាញសង្គម Facebook ផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា។

ដើម្បីឱ្យការប្រារព្ធពិធីនៃទិវាជាតិអំណានលើកទី៩ ១១ មីនា ២០២៤ ប្រព្រឹត្តទៅដោយរលូន និងអធិកអធម ក្រសួងបានរៀបចំឱ្យមានកម្មវិធីសំខាន់ៗ ដូចជា ៖

១- ប្រឡងប្រជែងអាន ស្ធូតកំណាព្យ និងតែងនិពន្ធ «**ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន**»

២- ប្រឡងប្រជែងបកស្រាយប្រធានបទ «**តួនាទីព្រះពុទ្ធសាសនាក្នុងការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌**»

៣- បាឋកថាស្រាវជ្រាវស្តីពី «**តួនាទីអំណានក្នុងការលើកកម្ពស់គុណភាពអប់រំ និងសាលារៀនគំរូ**»

៤- វេទិកាពិភាក្សាតុមូលលើប្រធានបទ «**អំណានជាមូលដ្ឋានគ្រឹះសម្រាប់ទាំងអស់គ្នាក្នុងជីវិត**»

៥- ការតាំងពិព័រណ៍សៀវភៅរយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី៩ ដល់ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤។

## I. **គោលបំណង**

ការប្រារព្ធទិវាជាតិអំណានលើកទី៩ ក្រោមប្រធានបទ «**អំណានជាមូលដ្ឋានគ្រឹះសម្រាប់ទាំងអស់គ្នាក្នុងជីវិត**» មានគោលបំណងដូចខាងក្រោម៖

១- បណ្តុះទម្លាប់អាន ជំរុញវប្បធម៌អាន លើកកម្ពស់សមត្ថភាពអាន ស្ធូតកំណាព្យ និងការតែងនិពន្ធ សំដៅរួមចំណែកការពារ និងពង្រឹងវប្បធម៌ អរិយធម៌ខ្មែរ ដល់សិស្ស និស្សិត មន្ត្រីរាជការ ប្រជាជនគ្រប់រូបក្នុងប្រទេសកម្ពុជា ព្រមទាំងលើកកម្ពស់ រក្សាគុណតម្លៃកេរដំណែលរបស់មនុស្សជាតិ

២- ជំរុញឱ្យការអានក្លាយជាទម្លាប់សម្រាប់ប្រជាជនកម្ពុជាគ្រប់រូប ដើម្បីរួមចំណែកសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលធានាគុណភាពអប់រំប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា

៣- លើកកម្ពស់គុណភាពអប់រំ ចាប់ពីមត្តេយ្យសិក្សា ដល់មធ្យមសិក្សា ក្នុងគោលដៅរួមចំណែកអភិវឌ្ឍធនធានមនុស្ស សម្រាប់កសាងសង្គមកម្ពុជាឱ្យមានវិបុលភាព និងការអភិវឌ្ឍជានិរន្តរ៍។

## ពាក្យស្លោកសម្រាប់ទិវាជាតិអំណាន លើកទី៩

១. ដាក់ចុះទូរសព្ទចាប់យកសៀវភៅអាន
២. ចូលរួមទាំងអស់គ្នាដើម្បីបណ្ដុះទម្លាប់អាន
៣. កែលម្អវិធីសាស្ត្របង្រៀនដើម្បីលើកម្ពស់អំណាន
៤. អំណានជាគន្លឹះជោគជ័យនៃការសិក្សា
៥. អំណានដើម្បីលើកម្ពស់បំណិនសតវត្សទី២១
៦. បណ្ដុះទម្លាប់អាន ជំរុញវប្បធម៌អាន
៧. អានដើម្បីភាពសុខដុមនៃជីវិត
៨. អំណានជាកំណាប់វិជ្ជាមហាសាល
៩. ការអានបណ្ដុះវប្បធម៌ការសិក្សាពេញមួយជីវិត
១០.ការអានបណ្ដុះបញ្ញា ការស្រាវជ្រាវ និងនវានុវត្តន៍
១១.អំណានជួយលើកកម្ពស់គុណភាពជីវិតក្នុងសង្គមឌីជីថល
១២.អំណានជាមាគ៌ាឆ្ពោះទៅបរិវត្តកម្មវិស័យអប់រំ
១៣.សសេរចំណាន អានចំណាប់ ចាប់យកចំណេះ។

## II. យុទ្ធវិធី

ដើម្បីឱ្យការប្រារព្ធទិវាជាតិអំណានលើកទី៩ ១១ មីនា ២០២៤ បានប្រព្រឹត្តទៅដោយរលូន និងទទួលបានលទ្ធផលគាប់ប្រសើរ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំយន្តការសំខាន់ៗតាមដំណាក់កាលដូចខាងក្រោម ៖

**១- ការត្រៀមរៀបចំប្រារព្ធពិធីទិវាជាតិអំណានលើកទី៩**

ក. ការប្រជុំពិភាក្សា ត្រៀមរៀបចំប្រារព្ធទិវាជាតិអំណានលើកទី៩ ១១ មីនា ២០២៤
ខ. ការរៀបចំលិខិតរដ្ឋបាលផ្សេងៗ សម្រាប់ជំរុញ និងគាំទ្រការប្រារព្ធទិវាជាតិអំណាន
គ. ការរៀបចំគណៈកម្មការផ្សេងៗសម្រាប់គ្រប់គ្រង និងដឹកនាំការប្រារព្ធទិវាជាតិអំណាន

**២- ការប្រឡងប្រជែងជ្រើសរើសបេក្ខជនជ័យលាភី**

ក. ការប្រឡងប្រជែង អានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធ ថ្នាក់រាជធានី ខេត្ត
ខ. ការប្រឡងប្រជែង អានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធ ថ្នាក់ជាតិ
គ. ការប្រឡងប្រជែង បកស្រាយប្រធានបទ

**៣- ការរៀបចំស្ដង់តាំងពិព័រណ៍សៀវភៅ**

**៤- ការប្រារព្ធទិវាជាតិអំណាន**

## III. សកម្មភាព និងលទ្ធផលនៃការរៀបចំទិវាជាតិអំណានលើកទី៩

### ១.ការត្រៀមរៀបចំប្រារព្ធពិធីទិវាជាតិអំណានលើកទី៩

**ក. កិច្ចប្រជុំពិភាក្សា ត្រៀមរៀបចំប្រារព្ធពិធីទិវាជាតិអំណានលើកទី៩ ១១ មីនា ២០២៤**

**ក.១.** កិច្ចប្រជុំនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៣ ស្តីពី ការត្រៀមរៀបចំប្រារព្ធពិធីទិវាជាតិអំណានលើកទី៩ នៅសាលប្រជុំ ក ទីស្តីការក្រសួងអប់រំ យុវជន និងកីឡា ស្ថិតក្រោមការដឹកនាំពី **លោកជំទាវ ទន់ សារ៉ែម** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ជាមួយនឹងថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា។ ជាលទ្ធផលអង្គប្រជុំបានស្នើឡើងដូចខាងក្រោម៖

- ពិនិត្យលើប្រធានបទចំនួន៤ និងពាក្យស្លោកចំនួន២២
- រៀបចំសេចក្តីណែនាំស្តីពី ការប្រារព្ធទិវាជាតិអំណាន
- រៀបចំសេចក្តីណែនាំស្តីពី ការប្រឡងប្រជែងអាន ស្មូតកំណាព្យ និងតែងនិពន្ធ
- ទីតាំងប្រារព្ធពិធី
- កម្មវិធីប្រារព្ធទិវាជាតិអំណានលើកទី៩
- គណៈអធិបតីសម្រាប់ការប្រារព្ធពិធី
- និងវាគ្មិនកិត្តិយសកម្មវិធីប្រារព្ធទិវាជាតិអំណានលើកទី៩។

 

**ក.២** កិច្ចប្រជុំថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤ ស្តីពី ការរៀបចំផែនការសកម្មភាពការប្រារព្ធទិវាជាតិអំណានលើកទី៩ នៅទីស្តីការក្រសួងអប់រំ យុវជន និងកីឡា។ អង្គប្រជុំស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំក្រសួង និងនាយកដ្ឋានពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍សរុប៣០នាក់។ លទ្ធផលនៃកិច្ចប្រជុំនេះមាន៖

- ប្រធានបទ «**អំណានជាមូលដ្ឋានគ្រឹះសម្រាប់ទាំងអស់គ្នាក្នុងជីវិត**»
- ពាក្យស្លោកចំនួន ១៣
- ទីតាំងប្រារព្ធពិធីទិវាជាតិអំណានលើកទី៩ នឹងរៀបចំនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
- ចំនួនអ្នកចូលរួមប្រារព្ធទិវាអំណានចំនួន៤០០០នាក់
- រៀបចំការប្រឡងប្រជែងជ្រើសរើសបេក្ខជនជ័យលាភី ផ្នែកអាន ស្មូតកំណាព្យ និងតែងនិពន្ធ
- រៀបចំបាកថាស្រាវជ្រាវ
- រៀបចំវេទិកាពិភាក្សាតុមូល
- រៀបចំការតាំងពិព័រណ៍រយៈពេល៣ថ្ងៃចាប់ពីថ្ងៃទី៩ ដល់ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤




*រូបភាព កិច្ចប្រជុំថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៤*

### ខ. ការរៀបចំលិខិតបទដ្ឋានគតិយុត្ត និងលិខិតរដ្ឋបាលផ្សេងៗ

ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំលិខិតជាច្រើនដើម្បីគាំទ្រដំណើរការអនុវត្តមានដូចជា៖

- លិខិតលេខ ០១ អយក.សណន ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៤ ស្តីពី ការរៀបចំប្រារព្ធទិវាជាតិអំណានលើកទី៩
- លិខិតលេខ ០២ អយក.សណន ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៤ ស្តីពីការប្រឡងប្រជែងអាន ស្មូត្រកំណាព្យ និងតែងនិពន្ធ អបអរសាទរទិវាជាតិអំណាន ១១ មីនា
- លិខិតលេខ ០៣ អយក.សជណ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២៤ ស្តីពីការប្រឡងប្រជែងបកស្រាយប្រធានបទ « តួនាទីព្រះពុទ្ធសាសនាក្នុងការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌»
- លិខិតលេខ ០៤ អយក.សសរ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៤ ស្តីពី ការបង្កើតគណៈកម្មការគ្រប់គ្រង និងដឹកនាំរៀបចំទិវាជាតិអំណានលើកទី៩ ១១ មីនា ២០២៤
- លិខិតលេខ១០៨៩អយក.ឱទន ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពី ការបង្កើតគណៈកម្មការវាយតម្លៃដាក់ពិន្ទុការប្រឡងប្រជែងអាន ស្មូតកំណាព្យ តែងនិពន្ធ និងបកស្រាយប្រធានបទ
- លិខិតលេខ ០២ អយក.សប្រព ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៤ ស្តីពី ការប្រារព្ធទិវាជាតិអំណានលើកទី៩ ១១ មីនា ២០២៤។

## ២.ការប្រឡងប្រជែងជ្រើសរើសបេក្ខជនជ័យលាភី

### ក. ការប្រឡងប្រជែងជ្រើសរើសបេក្ខជនជ័យលាភីថ្នាក់ក្រោមជាតិ

បន្ទាប់ពីទទួលបានលិខិតលេខ ០២ អយក.សណន ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២៤ ស្តីពី ការប្រឡងប្រជែងអាន ស្មូតកំណាព្យ និងតែងនិពន្ធ រួចមក មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តទាំងអស់ បានសហការជាមួយរដ្ឋបាលក្រុង ស្រុក ខណ្ឌ ណែនាំដល់ការិយាល័យអប់រំ យុវជន និងកីឡា និងគ្រប់គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន រៀបចំការប្រឡងប្រជែង ដូចខាងក្រោម៖

- **ដំណាក់កាលទី១៖** ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ បាន សហការជាមួយអាជ្ញាធរមូលដ្ឋាន ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធ ផ្សព្វផ្សាយ និងរៀបចំកម្មវិធីប្រឡងប្រជែងអានអត្ថបទ ស្ទូតកំណាព្យ និងតែងនិពន្ធ យ៉ាងផុលផុស និងបញ្ជូនបេក្ខជនជាប់ចំណាត់ថ្នាក់លេខ១ ទាំងបីវិញ្ញាសា ទៅចូលរួមប្រឡងប្រជែងនៅថ្នាក់រាជធានី ខេត្ត រៀងៗខ្លួន។
- **ដំណាក់កាលទី២៖** មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តទាំងអស់ បានសហការជាមួយអាជ្ញាធរមូលដ្ឋាន ដៃគូអភិវឌ្ឍ និងមន្ត្រីជំនាញនៃមន្ទីរពាក់ព័ន្ធ រៀបចំកម្មវិធីប្រឡងប្រជែងអានអត្ថបទ ស្ទូតកំណាព្យ និងតែងនិពន្ធ ជ្រើសរើសបានជ័យលាភីថ្នាក់ខេត្ត លេខ១ ទាំងបីវិញ្ញាសា ទៅចូលរួមប្រឡងប្រជែងនៅថ្នាក់ជាតិ។



*រូបភាព ការប្រឡងប្រជែងតាមរាជធានី ខេត្ត*

## ខ. ការប្រឡងប្រជែងជ្រើសរើសបេក្ខជនជ័យលាភីថ្នាក់ជាតិ

### ខ.១- ពិធីបើកការប្រឡងប្រជែង អាន ស្មូតកំណាព្យ និងតែងនិពន្ធ

នៅថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៤ នៅសាលប្រជុំជាន់ទី១ អគាររដ្ឋបាលក្រសួងអប់រំ យុវជន និងកីឡា ចៅពញាហុក បានរៀបចំកម្មវិធីបើកការប្រឡងប្រជែង អាន ស្មូតកំណាព្យ និងតែងនិពន្ធជ្រើសរើសជ័យលាភីថ្នាក់ជាតិ ទទួល «**ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន**» ។ អង្គពិធីបានស្ថិតក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា ដោយមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី គណៈកម្មការវាយតម្លៃដាក់ពិន្ទុ ប្រតិភូតំណាងតាមរាជធានី ខេត្ត បេក្ខជន មាតាបិតា និងអាណាព្យាបាលបេក្ខជនសរុប២៥៣នាក់។ លោក **ស៊ុន ប៊ុណ្ណា** ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា បានឡើងធ្វើ របាយការណ៍វឌ្ឍនភាពនៃការប្រឡងប្រជែងអាន ស្មូតកំណាព្យ និងតែងនិពន្ធ ជូនគណៈអធិបតី និងអង្គពិធីទាំងមូលថា ការរៀបចំការប្រឡងប្រជែងសម្រាប់ឆ្នាំនេះទទួលបានបេក្ខជនសរុបចំនួន៧៥នាក់ ស្រីចំនួន៥៧នាក់ មកពី២៥រាជធានី ខេត្ត ដោយចែកចេញជាបីវិញ្ញាសាដូចជា ផ្នែកអានអត្ថបទ សរុបចំនួន២៥នាក់ស្រីចំនួន២៣នាក់ ផ្នែកស្មូតកំណាព្យ សរុបចំនួន២៥នាក់ស្រីចំនួន១៨នាក់ និងផ្នែកតែងនិពន្ធ សរុបចំនួន២៥នាក់ស្រីចំនួន១៦នាក់។ ដោយឡែកចំពោះការប្រឡងប្រជែងផ្នែកមហាជន បកស្រាយប្រធានបទ «តួនាទីព្រះពុទ្ធសាសនា ក្នុងការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌» មានការចូលរួមសរុបចំនួន១២១អង្គ/នាក់ ដែលមានសមាសភាពជាព្រះសង្ឃ មន្ត្រីរាជការ អ្នកសារព័ត៌មាន សិស្ស និស្សិត និងមហាជនផងដែរ។ ក្នុងឱកាសនោះដែរ ឯកឧត្តមបណ្ឌិតសភាចារ្យ ណាត ប៊ុនរឿន រដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា បានឡើងថ្លែងសុន្ទរកថាស្តីពី ការរៀបចំការប្រឡងប្រជែងនេះជាការរួមចំណែកលើតម្កើងវប្បធម៌ជាតិ ការផ្សារភ្ជាប់ ជំនាន់មនុស្សពីជំនាន់ក្មេងនិងជំនាន់ចាស់ ឱ្យខិតខំថែរក្សា ការពារ ផ្សព្វផ្សាយឈរលើស្មារតីអភិរក្សនិងអភិវឌ្ឍ។ ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋលេខាធិការ ក៏បានថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រីជាគណៈកម្មការវាយតម្លៃដាក់ពិន្ទុ ដែលអញ្ជើញមកពីក្រសួង ស្ថាប័នពាក់ព័ន្ធ ក៏ដូចជាក្រសួងអប់រំ យុវជន និងកីឡា ដែលបានចូលរួមនៅពេលនេះ។







*រូបភាព ពិធីប្រកាសបើកកម្មវិធីប្រឡងប្រជែងអាន ស្មូតកំណាព្យ និងតែងនិពន្ធ*

ចុងបញ្ចប់ **ឯកឧត្តមបណ្ឌិតសភាចារ្យ រដ្ឋលេខាធិការ** បានសំណូមពរដល់គណៈកម្មការវាយតម្លៃដាក់ពិន្ទុសូមកុំលម្អៀង និងបានប្រកាសបើកកម្មវិធីប្រឡងប្រជែងជ្រើសរើសបេក្ខជនជ័យលាភី អាន ស្មូតកំណាព្យ និងតែងនិពន្ធ។

**ខ.២- ដំណើរការប្រឡងប្រជែងអាន ស្មូតកំណាព្យ និងតែងនិពន្ធ**

ការប្រឡងប្រជែងជ្រើសរើសបេក្ខជនជ័យលាភីថ្នាក់ជាតិ ផ្នែកអានអត្ថបទ ស្មូតកំណាព្យ និងតែងនិពន្ធ ទទួល «**ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន**» បានប្រព្រឹត្តទៅដូចខាងក្រោម៖

**១-ការប្រឡងប្រជែងផ្នែក អាន**

ការប្រឡងប្រជែងផ្នែកអានបានរៀបចំ និងប្រព្រឹត្តទៅដូចខាងក្រោម៖

***១.១ សមាសភាពគណៈកម្មការវាយតម្លៃដាក់ពិន្ទុ***

- លោកជំទាវ **យុន រចនា** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា
- លោកជំទាវ **នង ធូក** អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន
- លោក **យឹម សារិន** អនុប្រនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា
- លោក **យ៉ង់ កំស៊ាន** ប្រធានការិយាល័យនា.អកស
- លោកស្រី **ផាន់ សុជាតា** មន្ត្រី នាយកដ្ឋាន.អកស

### ១.២ បេក្ខជនចូលរួមប្រឡងប្រជែង

បេក្ខជនសរុបចំនួន២៥នាក់ ស្រី២៣នាក់ ជាសិស្សកំពុងសិក្សានៅថ្នាក់ទី៤,៥, និងថ្នាក់ទី៦ មកពី២៥ រាជធានី ខេត្ត

### ១.៣ គោលការណ៍វិនិច្ឆ័យដាក់ពិន្ទុ

- អានអត្ថបទបានលឿន គោរពឃ្លា ល្បះបានត្រឹមត្រូវ ២ពិន្ទុ
- សំឡេង/សំនៀងច្បាស់ៗ ត្រឹមត្រូវតាមសូររបស់ពាក្យ ៣ពិន្ទុ
- មិនខុសពាក្យ មិនរំលងពាក្យ ៤ពិន្ទុ
- ឥរិយាបថសមរម្យ ១ពិន្ទុ

### ១.៤ សកម្មភាពប្រឡងប្រជែង

គណៈកម្មការវាយតម្លៃដាក់ពិន្ទុ បានណែនាំពីនីតិវិធីនៃការប្រឡងប្រជែង ដល់បេក្ខជនមុនពេលដំណើរការ។ បេក្ខជនម្នាក់ៗ ត្រូវអានអត្ថបទដែលគណៈកម្មការបានរៀបចំ សម្រាប់ការប្រឡងប្រជែង ម្តងម្នាក់ៗ រហូតដល់គ្រប់បេក្ខជនទាំងអស់។ គណៈកម្មការនីមួយៗ បានដាក់ពិន្ទុទៅតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ នៅលើសន្លឹកដែលបានរៀបចំទុកតាមឈ្មោះបេក្ខជននីមួយៗ បន្ទាប់មកបញ្ជូនទៅឱ្យលេខាបញ្ចូលពិន្ទុ ដើម្បីទទួលបានលទ្ធផលរបស់បេក្ខជន។



*រូបភាព សកម្មភាពប្រឡងប្រជែងផ្នែកអាន*

## ២.ការប្រឡងប្រជែង ស្មូតកំណាព្យ

ការប្រឡងប្រជែងស្មូតកំណាព្យ បានរៀបចំនិងប្រព្រឹត្តទៅដូចខាងក្រោមៈ

### *២.១ សមាសភាពគណៈកម្មការវាយតម្លៃដាក់ពិន្ទុ*

- លៈជ.បណ្ឌិត **សឿ សុជាតា** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា
- ឯកឧត្តម **យ៉ាន់ បូរិន** ទីប្រឹក្សាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- លោកស្រី **ម៉ម សុខលី** សាស្ត្រាចារ្យសាលាមធ្យមសិក្សាវិចិត្រសិល្បៈ
- លោក **សីហា ឧត្តម** នាយកក្លឹបអភិរក្សមរតកកំណាព្យខ្មែរ

### *២.២ បេក្ខជនចូលរួមប្រឡងប្រជែង*

បេក្ខជនសរុបចំនួន២៥នាក់ ស្រី១៨នាក់ ជាសិស្សកំពុងសិក្សានៅថ្នាក់ទី៧,៨, និងថ្នាក់ទី៩ មកពី២៥ រាជធានី ខេត្ត

### *២.៣ គោលការណ៍វិនិច្ឆ័យដាក់ពិន្ទុ*

- ស្មូតតាមលំនាំបទនៃកំណាព្យ ៤ពិន្ទុ
- ទឹកដមសំឡេងពីរោះក្រអៅក្រអួន ៣ពិន្ទុ
- សំឡេងមិនដាច់ មិនភ្លាត់ ឬភ្លាវនាំឱ្យខុសចង្វាក់ ២ពិន្ទុ
- ទឹកមុខកាយវិការទៅតាមបរិយាកាសនៃបទនីមួយៗ ១ពិន្ទុ

### *២.៤ សកម្មភាពប្រឡងប្រជែង*

ការគណៈកម្មការវាយតម្លៃដាក់ពិន្ទុបានណែនាំឱ្យពីនីតិវិធីនៃការប្រឡងប្រជែងដល់បេក្ខជនមុនពេលដំណើរការ។ បេក្ខជនម្នាក់ៗ ត្រូវស្មូតអត្ថបទកំណាព្យ ដែលបានរៀបចំមករៀងៗខ្លួន រហូតដល់គ្រប់បេក្ខជនទាំងអស់។ គណៈកម្មការនីមួយៗ បានដាក់ពិន្ទុទៅតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ នៅលើសន្លឹកដែលបានរៀបចំទុកតាមឈ្មោះបេក្ខជននីមួយៗ បន្ទាប់មកបញ្ចូលទៅឱ្យលេខាបញ្ចូលពិន្ទុ ដើម្បីទទួលបានលទ្ធផលរបស់បេក្ខជន។



*រូបភាព សកម្មភាពប្រឡងប្រជែងផ្នែកស្មូតកំណាព្យ*

## ៣.ការប្រឡងប្រជែង តែងនិពន្ធ

ការប្រឡងប្រជែងតែងនិពន្ធ បានរៀបចំនិងប្រព្រឹត្តទៅដូចខាងក្រោម៖

### *៣.១ សមាសភាពគណៈកម្មការវាយតម្លៃដាក់ពិន្ទុ*

- ឯកឧត្តម **ជ័យ ចាប** ទីប្រឹក្សាក្រសួងព្រះបរមរាជវាំង
- លោកជំទាវ **ទន់ សាអ៊ីម** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា
- លោក **សេង សំអាន** ទីប្រឹក្សាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- លោក **ឃិន ជី** អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា
- លោក **ព្រៃ សំបូរ** អនុប្រធានការិយាល័យនា.អកស

### *៣.២ បេក្ខជនចូលរួមប្រឡងប្រជែង*

បេក្ខជនសរុបចំនួន២៥នាក់ ស្រី១៦នាក់ ជាសិស្សកំពុងសិក្សានៅថ្នាក់ទី១០, ១១,និងថ្នាក់ទី១២ មកពី២៥ រាជធានី ខេត្ត

### *៣.៣ គោលការណ៍វិនិច្ឆ័យដាក់ពិន្ទុ*

- អត្ថរូប (រង្វាស់កាព្យ ចំណាប់ចួន ភាសាកាព្យ) ៣ពិន្ទុ
- អត្ថន័យ (ត្រឹមត្រូវតាមប្រធានបទ) ៣ពិន្ទុ
- អត្ថរស (តម្លៃអប់រំ តម្លៃគុណធម៌ និងតម្លៃសីលធម៌) ២ពិន្ទុ
- អក្ខរាវិរុទ្ធ ២ពិន្ទុ

### *៣.៤ សកម្មភាពប្រឡងប្រជែង*

ការគណៈកម្មការវាយតម្លៃដាក់ពិន្ទុបានណែនាំឱ្យពីនីតិវិធីនៃការប្រឡងប្រជែងដល់បេក្ខជនមុនពេលដំណើរការ។ បេក្ខជនម្នាក់ៗ ត្រូវតែងកំណាព្យថ្មី ស្របតាមប្រធានបទដែលគណៈកម្មការបានដាក់ជូន និងមិនត្រូវចម្លងកំណាព្យដែលធ្លាប់តែងនិពន្ធរួចដាក់ចូលក្នុងសន្លឹកកិច្ចការឡើយ។ គណៈកម្មការនីមួយៗ បានដាក់ពិន្ទុទៅតាមលក្ខណៈវិនិច្ឆ័យដែលបានកំណត់ នៅលើសន្លឹកកិច្ចការរបស់បេក្ខជននីមួយៗ បន្ទាប់មកបញ្ជូនទៅឱ្យលេខាបញ្ចូលពិន្ទុ ដើម្បីទទួលបានលទ្ធផលរបស់បេក្ខជន។



*រូបភាព សកម្មភាពប្រឡងប្រជែងផ្នែកតែងនិពន្ធ*

## ៤.ការប្រឡងប្រជែងបកស្រាយប្រធានបទ

ការពិនិត្យ និងវាយតម្លៃស្នាដៃបកស្រាយប្រធានបទ បានរៀបចំ និងប្រព្រឹត្តទៅដូចខាងក្រោម៖

### *៤.១ សមាសភាពគណៈកម្មការវាយតម្លៃដាក់ពិន្ទុ*

- ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** រដ្ឋលេខាធិការក្រសួង.អយក
- លោកជំទាវ **ទន់ សាអ៊ឹម** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា
- លោក **ឃិន ជី** អនុប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា
- លោក **ព្រៃ សំបូរ** អនុប្រធានការិយាល័យនា.អកស
- លោក **ងិន សុតារា** អនុប្រធានការិយាល័យនា.អកស
- លោក **សុខ បញ្ញាវឌ្ឍន៍** អនុប្រធានការិយាល័យនា.អកស

### *៤.២ បេក្ខជនចូលរួមប្រឡងប្រជែង* សរុបចំនួន១២១ អង្គ/នាក់

### *៤.៣ គោលការណ៍វិនិច្ឆ័យដាក់ពិន្ទុ*

- សេចក្ដីផ្ដើម ០.៥០ពិន្ទុ
- បញ្ញត្តិ ៣.០០ពិន្ទុ
- តួនាទីព្រះពុទ្ធសាសនា ៥.០០ពិន្ទុ
- សន្និដ្ឋាន ១.០០ពិន្ទុ
- រចនាបថ ០.៥០ពិន្ទុ

### *៤.៤ សកម្មភាពប្រឡងប្រជែង*

គណៈកម្មការវាយតម្លៃដាក់ពិន្ទុបានប្រមូលស្នាដៃរបស់បេក្ខជនដែលបានផ្ញើមក ដោយពិនិត្យ និងវាយតម្លៃលើគោលការណ៍វិនិច្ឆ័យដាក់ពិន្ទុយ៉ាងសុក្រឹត តម្លាភាព និងយុត្តិធម៌។ ការវាយតម្លៃបែងចែកជា៣ដំណាក់កាល គឺ ដំណាក់កាលទី១ ពិនិត្យលើស្នាដៃរបស់បេក្ខជនទាំងអស់ដែលស្របទៅតាមសេចក្ដីជូនដំណឹង ស្ដីពីការប្រឡងប្រជែង ដំណាក់កាលទី២ ជ្រើសរើសស្នាដៃដែលបានបកស្រាយល្អចំនួន១០ និងដំណាក់កាលទី៣ វាយតម្លៃជ្រើសរើសស្នាដៃចំនួន៥ ជាជ័យលាភីកិត្តិយស ដើម្បីអបអរសាទរទិវាជាតិអំណានលើកទី៩។



*រូបភាព សកម្មភាពគណៈកម្មការពិនិត្យ និងវាយតម្លៃ ផ្នែកបកស្រាយប្រធានបទ*

**គ. ការប្រកាសលទ្ធផលប្រឡងប្រជែងជ្រើសរើសបេក្ខជនជ័យលាភីថ្នាក់ជាតិ**

នាព្រឹកថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៤ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីប្រកាសលទ្ធផល និងបិទកម្មវិធីប្រឡងប្រជែង។

*គ.១ របាយការណ៍ស្តីពី លទ្ធផលនៃការប្រឡងប្រជែង*

**លោកជំទាវ ទន់ សារិទ្ធិម** អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា បានអានរបាយការណ៍ជូន **ឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** និងអង្គពិធីថា ការប្រឡងប្រជែងមានពីរផ្នែកគឺទី១-ការប្រឡងប្រជែងផ្នែកមហាជន បកស្រាយប្រធានបទ«**តួនាទីព្រះពុទ្ធសាសនាក្នុងការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌**» ដោយមានបេក្ខជនចូលរួមប្រឡងប្រជែង ចំនួន១២១អង្គ/នាក់ មានសមាសភាពជាព្រះសង្ឃ មន្ត្រីរាជការ អ្នកសារព័ត៌មាន សិស្ស និស្សិត និងមហាជន។ ទី២-ការប្រឡងប្រជែងជ្រើសរើសបេក្ខជនជ័យលាភីថ្នាក់ជាតិផ្នែក អាន ស្មូតកំណាព្យ និងតែងនិពន្ធ ទទួលពានរង្វាន់ «**ពានរង្វាន់សម្តេចតេជោ ហ៊ុន សែន**» មានបេក្ខជនមកពីរាជធានី ខេត្ត សរុបចំនួន៧៥នាក់ស្រី៥៧នាក់ ដោយបែងចែកជា៣វិញ្ញាសាគឺផ្នែកអាន ផ្នែកស្មូតកំណាព្យ និងផ្នែកតែងនិពន្ធ។ ដោយឡែកចំពោះដំណើរការប្រឡងប្រជែងបានប្រព្រឹត្តទៅដោយរលូន និងមានការយកចិត្តទុកដាក់ខ្ពស់ក្នុងការវាយតម្លៃដាក់ពិន្ទុចំពោះបេក្ខជននីមួយៗ គោរពទៅតាមគោលការណ៍ដាក់ពិន្ទុរបស់គណៈកម្មការ ដោយប្រកាន់ភ្ជាប់នូវភាពយុត្តិធម៌ និងតម្លាភាព។

*គ.២ ប្រសាសន៍សំណេះសំណាល និងប្រកាសលទ្ធផលនៃការប្រឡងប្រជែង*

**ឯកឧត្តម បណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** មានមតិស្វាគមន៍ដល់ ព្រះសង្ឃ ឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូ ព្រមទាំងបេក្ខជនទាំងអស់ដែលមានវត្តមានចូលរួមក្នុងកម្មវិធីនេះ។ **ឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** បានមានប្រសាសន៍បន្តទៀតថា ឆ្នាំនេះក្រសួងអប់រំ យុវជន និងកីឡា នឹងរៀបចំទិវាជាតិអំណានលើកទី៩ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ ដើម្បីលើកកម្ពស់ការបង្រៀនភាសាខ្មែរនៅកម្ពុជា។ ប្រធានបទឆ្នាំនេះគឺ «**អំណានជាមូលដ្ឋានគ្រឹះសម្រាប់ទាំងអស់គ្នាក្នុងជីវិត**»។ ការរៀបចំទិវាជាតិអំណាន មានគោលដៅលើកកម្ពស់ការរៀន លើកកម្ពស់អក្ខរកម្មភាសាខ្មែរ ការយល់ដឹងពីភាសា វប្បធម៌ និងអារ្យធម៌ខ្មែរ។ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំវិធានការជាកញ្ចប់ដើម្បីបង្កើតជាប្រព័ន្ធមួយសម្រាប់លើកកម្ពស់អំណាន ការសរសេរ និងអក្ខរកម្មភាសាខ្មែរ។ ការរៀបចំវិធីសាស្ត្របង្រៀនភាសាខ្មែរថ្មី ភាសាខ្មែរមានការវិវត្តច្រើនដំណាក់កាល ភាសានិយាយនិងភាសាសរសេរ។ ភាសាសរសេរបានរកឃើញសក្ខីកម្មជាច្រើន ជាពិសេសគឺនៅប្រាង្គប្រាសាទដែលមានក្នុងសិលាចារឹកសតវត្សទី៣ សរសេរជាភាសាសំស្ក្រឹត សតវត្សទី៦ទើបឃើញមានសរសេរជាភាសាខ្មែរចាស់ ដែលប្រើប្រាស់ពាក្យពេចន៍ជាច្រើន ជាភាសាសំស្ក្រឹតផ្សំជាមួយភាសាខ្មែរ ហៅថា

ខ្មែរមុនសម័យអង្គរ    រហូតដល់សតវត្សទី៩មានការផ្លាស់ប្តូរអក្ខរក្រមពីខ្មែរចាស់សម័យអង្គររហូតដល់ចុងសម័យអង្គរ ទើបមានការផ្លាស់ប្តូរម្តងទៀត។ ការផ្លាស់ប្តូរនូវរបបនយោបាយក៏ជះឥទ្ធិពលការផ្លាស់ប្តូរសាសនា និងភាសាផងដែរ។ ក្រោយសម័យអង្គរទើបបង្កើតបានជាភាសាខ្មែរកណ្តាលមាននៅលើសិលាចារឹកប្រាសាទអង្គរតែម្តង ដែលប្រើប្រាស់ភាសាបាលី ភាសាសំស្ក្រឹត និងភាសាខ្មែរចាស់រួមគ្នា។រហូតដល់ចុងសម័យសតវត្សទី១៧ ដើមសតវត្សទី១៨ ទើបឃើញសិលាចារឹកដែលយើងអាចអាននិងយល់បានច្រើនដែលមានលក្ខណៈជាភាសាខ្មែរ។ ដើមសតវត្សទី១៩ ចាប់ផ្តើមរៀបចំជា វចនានុក្រម **សម្តេចព្រះសង្ឃរាជ ជួន ណាត** បង្កើតភាសាខ្មែរមួយដែលមានស្តង់ដា។ មានការខ្ចីភាសាសំស្ក្រឹត និងភាសាបាលីបង្កើតជាអត្តសញ្ញាណភាសាខ្មែរ ប្រែក្លាយការអានពីភាសាបាលីជាភាសាខ្មែរ ទាំងអស់នេះជាចលនាភាសា ជាពិសេសនៅទសវត្សទី៦០ មានការបង្កើតខេមរយានកម្ម ក៏មានការវិវត្តបន្តទៀត។ នៅទសវត្សទី៨០ មានការសរសេរតាមបែបទំនាញសូរដែលបង្កើតឱ្យមានការសរសេរច្រើនបែប គឺតាមទំនាញសូរ និងអភិរក្សភាសាមុនទសវត្សទី៧០។

នៅឆ្នាំ២០០០ រាជរដ្ឋាភិបាលសម្រេចយកវចនានុក្រម **សម្តេចព្រះសង្ឃរាជ ជួន ណាត** ជាគោលក្នុងការអាន និងការសរសេរ។ ការបង្រៀនភាសាខ្មែរ មានវិធីសាស្ត្រពីរគឺ ទី១- វិធីសាស្ត្រតាមបែបប្រកបឬការស្គាល់សូរ ហៅថាវិធីសាស្ត្រស្គាល់សូរ ទី២-វិធីសាសាស្ត្រសរុប។ នៅឆ្នាំ២០១៥ ក្រសួងអប់រំ យុវជន និងកីឡា បានសម្រេចថា ដើម្បីលើកកម្ពស់ការអាននិងការសរសេរភាសាខ្មែរ ទី១-វិធីសាស្ត្របង្រៀនភាសាខ្មែរថ្មី ទី២-ការបណ្តុះបណ្តាលគ្រូ ទី៣-ជ្រើសរើសគ្រូល្អ នាយកល្អ ទី៤-ទិវាជាតិអំណាន (ការប្រឡងប្រជែង អាន ស្មូតកំណាព្យ និងតែងនិពន្ធ និងការប្រឡងប្រជែងបកស្រាយប្រធានផ្សេងៗ) ទី៥-កំណែទម្រង់សាលារៀន (វិធីសាស្ត្រអានក្នុងបណ្ណាល័យ ដើម្បីអានឱ្យស្គាល់សូរ ស្គាល់តួអក្សរ យល់ន័យ និងបណ្តុះទម្លាប់អាន បណ្ណាល័យត្រូវតែស្អាត និងមានសៀវភៅគ្រប់គ្រាន់) ទី៦-សិស្ស (ការបំប៉នសុខភាពសិស្ស អាហារូបត្ថម្ភ ទារកដ្ឋាន កុមារតូច) ទី៧-កត្តាឪពុកម្តាយ( ឱ្យតម្លៃទៅលើការអប់រំ បណ្ណាល័យ ជួយកូនក្នុងការរៀន) ទី៨- ឱកាសនៅក្នុងការបញ្ចេញស្នាដៃ។ **ឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ក៏បានផ្តាំផ្ញើដល់ក្មួយៗដែលជាយុវជនជំនាន់ក្រោយ ត្រូវរៀនសូត្រពីរៀមច្បង ក្នុងការសរសេរ ការស្មូត ការអភិរក្ស និងបន្តលើកជ្រោងទង់ភាសាខ្មែរឱ្យកាន់តែថ្កុំថ្កើងរុងរឿងជានិច្ចនិរន្តរ៍។










ជាកិច្ចបញ្ចប់ **ឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** ប្រកាសបេក្ខជនជ័យលាភីដូចខាងក្រោម៖

**ក- ផ្នែកអានអត្ថបទ**

១-ជ័យលាភីលេខ១ កុមារី ផល ដារីរក្សា សាលាបឋមសិក្សាស្នែត ខេត្តកំពង់ឆ្នាំង
២-ជ័យលាភីលេខ២ កុមារី យិ ធីតា សាលាបឋមសិក្សាដូនបុណ្យ ខេត្តកំពត
៣-ជ័យលាភីលេខ៣ កុមារី វណ្ណៈ សុម៉ាណែត សាលាបឋមសិក្សាស្មីកុមារ ខេត្តត្បូងឃ្មុំ

**ខ- ផ្នែក សូត្រកំណាព្យ**

១-ជ័យលាភីលេខ១ កុមារា សំអឿន សូណា អនុវិទ្យាល័យប្រម៉ា ខេត្តក្រចេះ
២-ជ័យលាភីលេខ២ កុមារី ឈិន បូរី អនុវិទ្យាល័យក្រាំងស្គារ ខេត្តកំពង់ឆ្នាំង
៣-ជ័យលាភីលេខ៣ កុមារា សុធី បញ្ញាវ័ន្ត អនុវិទ្យាល័យត្រពាំងទន្ទឹម ខេត្តព្រះវិហារ

**គ- ផ្នែក តែងនិពន្ធ**

១-ជ័យលាភីលេខ១ យុវជន ខាត់ នរិន្ទ សាលាចំណេះទូទៅឯកជនបុរីរដ្ឋា ខេត្តកំពង់ឆ្នាំង
២-ជ័យលាភីលេខ២ យុវតី ឈួ លីយាទ វិទ្យាល័យហ៊ុនសែនចំការដូង ខេត្តកែប
៣-ជ័យលាភីលេខ៣ យុវជន បូរិន ដាដារ៉ាន់ វិទ្យាល័យសោមធំ ខេត្តរតនគិរី

**ឃ-ជ័យលាភីផ្នែក បកស្រាយប្រធានបទ**

១-ជ័យលាភីលេខ១ ព្រះតេជគុណ យាន សំណាង ចៅអធិការវត្តចន្ទរង្សី ខេត្តក្រចេះ
២-ជ័យលាភីលេខ២ លោក មី សុវណ្ណ គ្រូបង្រៀនវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ
៣-ជ័យលាភីលេខ៣ លោក យុយ ម៉េងឃី គ្រូបង្រៀន វិ.ហស.ពាមជីកង ខេត្តកំពង់ចាម
៤-ជ័យលាភីលេខ៤ លោក សាត ឱច គ្រូបង្រៀនវិ.បរន.ហស ចរិយាវង្ស ខេត្តកែប
៥-ជ័យលាភីលេខ៥ លោក វុត សុវ៉ាន់ដា គ្រូបង្រៀន វិ.នេតយ៉ង់ ខេត្តបាត់ដំបង

**ឯកឧត្តមបណ្ឌិត សភាចារ្យឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរព្រះគុណ និងអរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមាន ព្រះតេជគុណ ឯកឧត្តម លោកជំទាវ លោក លោកស្រី បេក្ខជន លោកគ្រូ អ្នកគ្រូ ក្នុងអង្គពិធីទាំងមូល។

## ៣.ការតាំងពិព័រណ៍សៀវភៅ អបអរសាទរទិវាជាតិអំណានលើកទី៩

នារសៀលថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៤ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា បានរៀបចំពិធីសម្ពោធស្តង់តាំងពិព័រណ៍សៀវភៅ ស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** និងមានការចូលរួមពីថ្នាក់ដឹកនាំក្រសួង អង្គភាពថ្នាក់កណ្តាល និងក្រុមយុវជនស្ម័គ្រចិត្ត ប្រមាណ១០០នាក់។ ការរៀបចំតាំងពិព័រណ៍សៀវភៅនេះមានគោលបំណង អបអរសាទរការប្រារព្ធពិធីទិវាជាតិអំណានលើកទី៩ ១១ មីនា ២០២៤ ថែរក្សាអភិរក្សវប្បធម៌ អរិយធម៌ និងអក្សរសាស្ត្រខ្មែរ និងការផ្សារភ្ជាប់ជំនាន់មនុស្ស និងផ្សព្វផ្សាយដល់គ្រប់ស្រទាប់មហាជន ពីសមិទ្ធិផលជាស្នាដៃ របស់អ្នកនិពន្ធទាំងកម្រិតជាតិនិងអន្តរជាតិ ទាំងបរិមាណ ទាំងគុណភាពសៀវភៅ ព្រមទាំងមានការចូលរួមទស្សនា និងជាវសៀវភៅតាមតម្រូវការ។ នៅក្នុងឆ្នាំ២០២៤ មានការរៀបចំពិព័រណ៍សៀវភៅចំនួន៣ថ្ងៃចាប់ពីថ្ងៃទី៩ ដល់ថ្ងៃទី១១ ខែមីនា ដោយមានស្តង់ចំនួន១០៦ស្តង់ ស្មើ៥៦ស្ថាប័ន និងមានអ្នកចូលរួមប្រមាណ៦៦០០០នាក់។



## ៤. ការប្រារព្ធទិវាជាតិអំណានលើកទី៩ ១១ មីនា ២០២៤

ការប្រារព្ធទិវាជាតិអំណានលើកទី៩ ១១ មីនា ២០២៤ ក្រោមប្រធានបទ «**អំណានជាមូលដ្ឋានគ្រឹះសម្រាប់ទាំងអស់គ្នាក្នុងជីវិត**» បានប្រព្រឹត្តទៅនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ ថ្នាក់ដឹកនាំមន្ទីរ២៥ រាជធានី ខេត្ត លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និស្សិត សរុបប្រមាណ ២០០០ នាក់។

*ក- របាយការណ៍វឌ្ឍនភាពស្តីពី «ការរៀបចំទិវាជាតិអំណានចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២៣»*

បន្ទាប់ពីការធ្វើគារវកិច្ចស្វាគមន៍ ទៅដល់គណៈអធិបតី និអង្គពិធីទាំងមូលរួចមក លោក **ស៊ុន ប៊ុណ្ណា** ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា បានធ្វើរបាយការណ៍ជូន **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** និងអង្គពិធីដោយមានខ្លឹមសារដូចខាងក្រោម៖ ការបង្ហាញពីកម្មវិធីនានា និងប្រធានបទដែលមាននៅក្នុងការរៀបចំប្រារព្ធទិវាជាតិអំណានទាំង៨លើករួចមកហើយ ដែលក្នុងនោះមានកម្មវិធីសំខាន់ៗដូចជា ការប្រឡងប្រជែង អានអត្ថបទ ស្មូតកំណាព្យ តែងនិពន្ធ ការបកស្រាយប្រធានបទផ្សេងៗ ការតាំងពិព័រណ៍សៀវភៅ បាឋកថាស្រាវជ្រាវ និងវេទិកាពិភាក្សាដែលមានការចូលរួមពីវាគ្មិនល្បីៗ។









*ខ- សុន្ទរកថាបើកការប្រារព្ធពិធីទិវាជាតិអំណានលើកទី៩ ១១ មីនា ២០២៤*

ក្នុងឱកាសនេះ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** មានប្រសាសន៍បើកការប្រារព្ធទិវាជាតិអំណានលើកទី៩ មានខ្លឹមសារសំខាន់ៗដូចតទៅ ការសំដែងនូវការស្វាគមន៍ ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និស្សិត និងគរុសិស្សទាំងអស់ ដែលបានចូលរួមក្នុងពិធីប្រារព្ធទិវាជាតិអំណាន ក្រោមប្រធានបទ «**អំណានជាមូលដ្ឋានគ្រឹះសម្រាប់ទាំងអស់គ្នាក្នុងជីវិត**»។ ប្រធានបទឆ្នាំ២០២៤នេះ ជាប្រធានបទមួយឆ្លុះបញ្ចាំងឱ្យឃើញពីសារៈសំខាន់នៃអំណាន ដើម្បីបណ្តុះនូវមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ឈានទៅរកជីវិតល្អប្រសើរសម្រាប់មនុស្សគ្រប់ៗគ្នា អំណានមិនត្រឹមតែផ្តោតទៅលើការទទួលបានព័ត៌មាននោះទេ អំណាននាំមកនូវការពង្រឹងចំណេះដឹង ការយល់ដឹងទស្សនៈរបស់អ្នកអានផងដែរ។ ការអានបង្កលក្ខណៈឱ្យយើងអាចស្វែងរកឃើញគំនិតថ្មីៗស្វែងយល់ពីវប្បធម៌ជាតិ អន្តរជាតិ បទពិសោធល្អៗ ដែលនាំទៅរកការរីកចម្រើន និងការអភិវឌ្ឍផ្ទាល់ខ្លួន។ តាមរយៈការអានបង្កើនបំណិនអក្ខរកម្មនិងធ្វើការប្រាស្រ័យទាក់ទងគ្នាបានល្អប្រសើរឡើងប្រកបដោយប្រសិទ្ធភាព ការត្រិះរិះពិចារណា ការដោះស្រាយបញ្ហាក្នុងជីវិតសព្វថ្ងៃ និងនៅពេលអនាគត។ ជារួមការអានជាមូលដ្ឋានគ្រឹះសម្រាប់ជីវិតកាន់តែប្រសើរឡើងសម្រាប់ទាំងអស់គ្នា និងផ្តល់នូវភាពអង់អាចក្លាហានដល់បុគ្គលម្នាក់ៗឈានទៅផ្តល់សក្តានុពលពេញលេញ និងរួមចំណែកជាវិជ្ជមាននៅក្នុងសង្គម។ នៅក្នុងយុគសម័យបច្ចេកវិទ្យាការអានក៏មានលក្ខណៈពិសេសផងដែរ យុវជនជាច្រើនបានប្រើប្រាស់បច្ចេកវិទ្យាដើម្បីលើកកម្ពស់អំណាន។ អំណានក្នុងយុគសម័យឌីជីថល ឬ អក្ខរកម្មឌីជីថល មិនមែនត្រឹមតែផ្តោតទៅលើការអានសៀវភៅ ឬ ការអានអក្សរតែមួយនោះទេ។ អក្ខរកម្មឌីជីថល គឺការរួមផ្សំរវាងអំណានអក្ខរកម្មជាមួយបច្ចេកវិទ្យា ហើយអក្ខរកម្មហិរញ្ញវត្ថុក៏ជួយដល់អ្នកអាននៅក្នុងការធ្វើឱ្យជីវិតកាន់តែល្អប្រសើរ។ ជារួមអំណាន គឺអានដើម្បីចាប់យកចំណេះដឹង ចាប់យកចំណេះធ្វើ ធ្វើឱ្យមនុស្សយើងសម្រេចបាននូវចរិយាធម៌ គុណធម៌ ហើយក្លាយជាពលរដ្ឋកម្ពុជាល្អ ក៏ដូចជាពលរដ្ឋសកលល្អ ដែលជាគោលដៅនៃកម្មវិធីអប់រំរបស់កម្ពុជា។ **ឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយរដ្ឋមន្ត្រី** ស្វាគមន៍ចំពោះវត្តមានឯកឧត្តម លោកជំទាវ លោក លោកស្រី សិស្ស និស្សិត លោកគ្រូ អ្នកគ្រូ ដៃគូអភិវឌ្ឍក្នៀវជាតិ អន្តរជាតិ ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ចូលរួមគាំទ្រក្នុងការរៀបចំទិវាជាតិអំណានឱ្យទទួលបានជោគជ័យក្នុងគោលដៅលើកម្ពស់គុណតម្លៃអំណានសម្រាប់ការអភិវឌ្ឍមូលធនមនុស្សនៅកម្ពុជា។ ជាពិសេសបានចូលរួមចំណែកជាមួយវិស័យអប់រំនៅក្នុងការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែល **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** បានដាក់ចេញសម្រាប់រាជរដ្ឋាភិបាលនីតិកាលទី៧។ ដើម្បីញ៉ាំងឱ្យគុណភាពជីវិតមានគុណភាពប្រជាពលរដ្ឋកម្ពុជាគ្រប់រូបមានភាពសម្បូរសប្បាយចម្រើនរុងរឿងជានិរន្តរ៍។ តាមរយៈការស្រាវជ្រាវបានបង្ហាញឱ្យឃើញថា ការបណ្តុះវប្បធម៌អានសៀវភៅ ធ្វើឱ្យមនុស្សមានសុខភាពខួរក្បាលល្អ កាត់បន្ថយស្ត្រេស អានកាន់តែច្រើនកាន់តែ

ក្មេងឡើង ចេះត្រិះរិះពិចារណាឱ្យបានស៊ីជម្រៅមានចំណេះដឹងទូលំទូលាយ បង្កើតភាពច្នៃប្រឌិត ទទួលបានគំនិតល្អៗទាន់សម័យកាលប្រើប្រាស់ក្នុងជីវិតរស់នៅ ឆ្ពោះទៅកាន់សង្គមពុទ្ធិ ត្រូវបណ្ដុះទម្លាប់អានសៀវភៅដើម្បីក្លាយជាគំរូល្អសម្រាប់ក្មេងជំនាន់ក្រោយ។






*គ- ពិធីប្រគល់ពានរង្វាន់ជ័យលាភី*

ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានប្រគល់ជូន «**ពានរង្វាន់សម្ដេចតេជោ ហ៊ុន សែន**» ប្រកាសនីយបត្រ និងប្រាក់រង្វាន់លើកទឹកចិត្ត សម្រាប់បេក្ខជនជ័យលាភីផ្នែកអានអត្ថបទ ស្មូតកំណាព្យ តែងនិពន្ធ និងបេក្ខជនជ័យលាភីផ្នែកបកស្រាយប្រធានបទ មានដូចខាងក្រោម៖

**១. ជ័យលាភីផ្នែក អានអត្ថបទ**

**ជ័យលាភីលេខ២** | **ជ័យលាភីលេខ១** | **ជ័យលាភីលេខ៣**


កុមារី **ឃិ ធីតា**


កុមារី **ផល ដារីរក្សា**


កុមារី **វណ្ណៈ សុម៉ាណៃ**

២.ជ័យលាភីផ្នែក ស្មូតកំណាព្យ

ជ័យលាភីលេខ២



កុមារី ឈិន បូរី

ជ័យលាភីលេខ១



កុមារ សំអឿន សូណា

ជ័យលាភីលេខ៣



កុមារ សុធី បញ្ញាវ័ន្ត

៣.ជ័យលាភីផ្នែក តែងនិពន្ធ

ជ័យលាភីលេខ២



យុវតី ឈួ លីយាទ

ជ័យលាភីលេខ១



យុវជន ខាត់ នរិន្ទ

ជ័យលាភីលេខ៣



យុវជន បូរិន ជាដារ៉ាន់

៤.ជ័យលាភីផ្នែក បកស្រាយប្រធានបទ

ជ័យលាភីលេខ២



លោក មី សុវណ្ណ

ជ័យលាភីលេខ១



ព្រះតេជគុណ យាន សំណាង

ជ័យលាភីលេខ៣



លោក យុយ ម៉េងឃី

ជ័យលាភីលេខ៤

លោក សាត ឱត





ជ័យលាភីលេខ៥

លោក វុត សុវ៉ាន់ដា

- ❖ ការអានអត្ថបទដោយ កុមារី **ផល ដារីរក្សា** ជ័យលាភីលេខ១ ផ្នែកអានអត្ថបទ មានចំណងជើងថា «**សរសេរចំណាន អានចំណាប់ ចាប់យកចំណេះ**»។
- ❖ ការសូត្រកំណាព្យដោយ កុមារា **សំអឿន សូណា** ជ័យលាភីលេខ១ ផ្នែកសូត្រកំណាព្យ មានចំណងជើងថា «**អំណាន លើកកម្ពស់គុណវុឌ្ឍិ និងគុណធម៌**» ជាស្នាដៃនិពន្ធរបស់យុវជន **ខាត់ នរិន្ទ** ជាបេក្ខជនជ័យលាភីលេខ១ ផ្នែកតែងនិពន្ធ។

*ឃ- ការឧបត្ថម្ភ*

ការប្រារព្ធទិវាជាតិអំណានលើកទី៩ ទទួលបានការឧបត្ថម្ភពីៈ

- ឯកឧត្តម **ពេជ សោភ័ន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានលេខាធិការដ្ឋាន គ.វ.អ ថវិកា ២.០០០.០០០ រៀល
- ឯកឧត្តម **សុខ សារាវុឌ្ឍ** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ថវិកា ១.០០០.០០០ រៀល
- ឯកឧត្តម **ឈួរ សុបញ្ញា** រដ្ឋលេខាធិការក្រសួងមុខងារសាធារណៈ ថវិកា១.០០០.០០០ រៀល
- ឯកឧត្តម **ហៃ ហ៊ុនឡេង** សមាជិកលេខាធិការដ្ឋាន គ.វ.អ និងជានាយកខុទ្ទកាល័យឯកឧត្តម ពេជ សោភ័ន ថវិកា ៥០០.០០០ រៀល
- លោកជំទាវបណ្ឌិត **សឿ សុជាតា** អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ថវិកា ៥០០.០០០ រៀល

***ង- បាឋកថាស្រាវជ្រាវស្តីពី «តួនាទីអំណានក្នុងការលើកកម្ពស់គុណភាពអប់រំ និងសាលារៀនគំរូ»***

បាឋកថាស្រាវជ្រាវស្តីពី«**តួនាទីអំណានក្នុងការលើកកម្ពស់គុណភាពអប់រំ និងសាលារៀនគំរូ**»ដោយ លោកបណ្ឌិត **កាន់ ពុទ្ធី** អនុប្រធាននាយកដ្ឋានបឋមសិក្សា បាឋកថានេះមានគោលបំណងលើកកម្ពស់អំណានថ្នាក់ដំបូងនៅកម្ពុជា ដែលជាមូលដ្ឋានគ្រឹះសម្រាប់បន្តរៀននៅថ្នាក់បន្តបន្ទាប់ទៀត នៅក្នុងករណីដែលសិស្សមិនអាចអាននៅថ្នាក់ទី១ទេ មិនអាចបន្តទៅរៀនថ្នាក់ទី២ ឬទី៣ទេ ហើយនៅពេលដែលឡើងថ្នាក់បន្តបន្ទាប់ទៀតអាចប្រឈមនឹងការបោះបង់ការសិក្សា ដែលនៅក្នុងនោះដែរលោកបណ្ឌិតលើកយក៥ចំណុចមកបង្ហាញដូចខាងក្រោមៈ

១-បង្ហាញពីសេចក្តីផ្តើម និយាយពីគុណភាពអប់រំ និងសាលារៀនគំរូ

២-សារតារ ការផ្លាស់ប្តូរប្រព័ន្ធអប់រំ បង្កើតសៀវភៅភាសាខ្មែរថ្នាក់ទី១ សៀវភៅភាសាខ្មែរអាន-សរសេរថ្នាក់ទី១ ការរៀបកញ្ចប់សម្ភារៈអំណានថ្នាក់ដំបូង។

៣-គោលការណ៍អភិវឌ្ឍកញ្ចប់សម្ភារៈអំណានថ្នាក់ដំបូង មានគោលការណ៍នៃការអភិវឌ្ឍសៀវភៅជំនួយសិស្ស និងសៀវភៅរឿងខ្លីៗមាន៦ចំណុចគឺ ការអនុវត្តបំណិនក្នុងការអាន ការបង្រៀនអានអត្ថបទងាយៗ ការអភិវឌ្ឍភាសា ការអនុវត្តតាមវឌ្ឍនភាពនៃបំណិនអាន និងសរសេរជាប្រព័ន្ធ ការបង្កើតវិសាលភាពនិងលំដាប់លំដោយ ការចងក្រងខ្លឹមសារបង្រៀនស្របតាមគោលការណ៍កុមារមេត្រី និងបរិយាបន្ន។ ការអភិវឌ្ឍសមត្ថភាពគ្រូ

បង្រៀន មានបីចំណុចគឺ ការរៀបចំសៀវភៅណែនាំគ្រូ ការបង្រៀនស្របតាមសមត្ថភាពសិស្ស និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ។ ការគាំទ្ររបស់រាជរដ្ឋាភិបាល គឺគាំទ្រទៅលើប្រព័ន្ធអប់រំ។

៤- ការអភិវឌ្ឍនិងអនុវត្តកញ្ចប់សម្ភារៈថ្នាក់ដំបូង មានគោលបំណង រៀបចំកញ្ចប់សម្ភារៈអំណានថ្នាក់ទី១ កញ្ចប់សម្ភារៈអំណានថ្នាក់ទី២ និងកញ្ចប់សម្ភារៈអំណានថ្នាក់ទី៣។ បង្ហាញពីវិសាលភាពនៃការអនុវត្ត លទ្ធផលនៃការអនុវត្ត បញ្ហាប្រឈម ទិសដៅបន្ត។

៥- ការធ្វើសេចក្តីសន្និដ្ឋាន។





## *ច- កម្មវិធីពេលរសៀល*

ការប្រារព្ធទិវាជាតិអំណានលើកទី៩ នារសៀល ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ បានស្ថិតក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** និងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំក្រសួង មន្ទីរអយក. រាជធានី ខេត្ត ដៃគូអភិវឌ្ឍជាតិ អន្តរជាតិ លោកគ្រូ អ្នកគ្រូ សិស្ស និស្សិត ទាំងគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន សរុប១៥០០ នាក់។

- ❖ ការសូត្រកំណាព្យដោយ កុមារី **ឈឺន បូរី** ជាជ័យលាភីលេខ២ ផ្នែកសូត្រកំណាព្យ មានចំណងជើងថា «**អំណាន លើកកម្ពស់គុណវុឌ្ឍិ និងគុណធម៌**» ជាស្នាដៃនិពន្ធរបស់យុវតី **ឈួ លីយាទ** ជាបេក្ខជនជ័យលាភីលេខ២ ផ្នែកតែងនិពន្ធ។

## *ឆ- វេទិកាពិភាក្សាតុមូល*

វេទិកាពិភាក្សាតុមូល**ស្តីពី «អំណានជាមូលដ្ឋានគ្រឹះសម្រាប់ទាំងអស់គ្នាក្នុងជីវិត»** ត្រូវបានសម្របសម្រួលដោយ លោកជំទាវបណ្ឌិត **ឃួន វិច្ឆិកា** អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងមានការអញ្ជើញចូលរួមជាវាគ្មិនកិត្តិយសក្នុងឱកាសនោះរួមមាន៖

**១- ព្រះមេធានុរ័ក្ខ គូ សុភាព ព្រះធម្មធរគណរាជធានីភ្នំពេញ «ព្រះពុទ្ធសាសនាចូលរួមអភិវឌ្ឍចំណេះដឹងប្រកបដោយគុណធម៌សម្រាប់ប្រទេសជាតិ»**

២- ឯកឧត្តម បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា *«ការកែលម្អវិធីសាស្ត្របង្រៀនភាសាខ្មែរ ដើម្បីលើកម្ពស់អំណាននៅកម្ពុជា»*

៣- ឯកឧត្តមបណ្ឌិត **ហ៊ាន សុខុម** ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ នៃរាជបណ្ឌិត្យសភាកម្ពុជា គោលការណ៍ចម្បងនៃការអាន *«សារៈសំខាន់បំណិនមូលដ្ឋាន និងយុទ្ធសាស្ត្រ»*





វេទិកាពិភាក្សានេះ លោកជំទាវបណ្ឌិតជាអ្នកសម្របសម្រួល បានបង្ហាញពីជីវប្រវត្តិ ព្រះតេគុណ ព្រះមេធានុរ័ក្ខ **គូ សុភាព** ព្រះធម្មធរគណរាជធានីភ្នំពេញ បានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតឯកទេសភាពជាអ្នកដឹកនាំពីសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងបានផ្លាស់ប្តូរការសិក្សានៅសាកលវិទ្យាល័យត្រយ សហរដ្ឋអាមេរិច ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ បច្ចុប្បន្នជាព្រឹទ្ធបុរសមហាវិទ្យាល័យ សិល្បៈ មនុស្សសាស្ត្រនិងភាសានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងជាសាស្ត្រាចារ្យបង្រៀនមុខវិជ្ជាបណ្តុះគុណធម៌ ចរិយាធម៌និងភាពជាអ្នកដឹកនាំ។ ព្រះតេជគុណបានបោះពុម្ពសៀវភៅអប់រំផ្លូវចិត្តជាច្រើន សៀវភៅអាហារផ្លូវចិត្ត ជំនួយសុខភាពផ្លូវចិត្ត មង្គលជីវិតជាដើម ដែលជាអត្ថបទដកស្រង់ចេញពីព្រះត្រៃបិដក។

**ឯកឧត្តម បណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** បានសរសេរសៀវភៅជាច្រើនជាភាសាខ្មែរ បារាំង និងភាសាអង់គ្លេស ដែលសរុបទាំងអស់ចំនួន ៣៨ ចំណងជើង ហើយសៀវភៅទី៣៨មានចំណងជើងថាការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំ។ និង**ឯកឧត្តម បណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** អាចប្រើប្រាស់ភាសាបរទេសបាន ដូចជាភាសាខ្មែរ បារាំង អង់គ្លេស រុស្ស៊ី ថៃ ចិន និងមានគោលបំណងរៀនភាសាបរទេសមួយទៀត។

ឯកឧត្តមបណ្ឌិត **ហ៊ាន សុខុម** ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ នៃរាជបណ្ឌិត្យសភាកម្ពុជា បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ពីសាកលវិទ្យាល័យមិត្តភាពប្រជាជាតិក្រុងមូស្គូ និងថ្នាក់បណ្ឌិតនិរុត្តិវិទ្យា ពីវិទ្យាស្ថានបូព៌ាសាស្ត្រ នៃបណ្ឌិត្យសភាវិទ្យាសាស្ត្រសហព័ន្ធរុស្ស៊ីក្រុងមូស្គូ។ **ឯកឧត្តមបណ្ឌិត** ធ្លាប់បំពេញការងារនៅក្នុងក្រសួងអប់រំ យុវជន និងកីឡា បំពេញការងារជាច្រើនផ្នែកស្រាវជ្រាវ និងបង្រៀនផងដែរ។ ឯកឧត្តមនិពន្ធសៀវភៅជាច្រើន ដែលក្នុងនោះ ឯកឧត្តមបានរៀបចំចងក្រងសៀវភៅវចនានុក្រមឆ្នាំ២០២២ ផងដែរ។

ព្រះមេធានុរ័ក្ខ **គូ សុនាព** ព្រះធម្មធរគណរាជធានីភ្នំពេញបានបង្ហាញពី «**ព្រះពុទ្ធសាសនាចូលរួមអភិវឌ្ឍចំណេះដឹងប្រកបដោយគុណធម៌សម្រាប់មនុស្សជាតិ**» ព្រះអង្គបានមានសង្ឃដីកាថាព្រះអង្គបានអានសៀវភៅអធិប្បាយសាសនសុភាសិតដែលនិយាយពីធម៌ខ្លីៗ ក្រោយពេលអានរួចក៏ជ្រះថ្លារួចក៏បួសជាព្រះសង្ឃ។ បន្ទាប់មកព្រះតេជគុណក៏បានបង្ហាញ ប្រភពនៃបញ្ញាមានបីគឺ ទី១- **សិតមយបញ្ញា** បញ្ញាកើតពីការស្តាប់ អាន សិក្សាស្រាវជ្រាវ ទី២- **ចិនតមយបញ្ញា** បញ្ញាកើតពីការត្រិះរិះពិចារណា ទី៣- **ភាវនាមយបញ្ញា** បញ្ញាកើតពីការធ្វើឱ្យបានច្រើនដងៗ វុទ្ធិធម៌ (ធម៌នាំឱ្យចម្រើន)មានបួនគឺ ទី១- **សប្បុរិសូបសំសេវៈ** សេពគប់មនុស្សល្អ សេពគប់មនុស្សត្រូវ ទី២- **ធម្មសវនៈ** ស្តាប់រៀនដោយយកចិត្តទុកដាក់ ទី៣- **យោនិសមនសិការៈ** ធ្វើទុកក្នុងចិត្តត្រូវត្រិះរិះពិចារណា ទី៤- **ធម្មានុធម្មប្បដិបត្ត** អនុវត្តធ្វើតាមធម៌ដែលបានរៀន។ អង្គរបស់អ្នករៀន គឺ កុំមើលងាយគ្រូ កុំមើលងាយមេរៀន កុំមើលងាយខ្លួនឯង រៀនដោយយកចិត្តទុកដាក់ និងគិតពិចារណា។ ព្រះអង្គបានមានសង្ឃដីកាបន្តទៀតថា មង្គលសូត្រមានបួនគឺ ទី១-**ពាហុសច្ចៈ** រៀនឱ្យបានច្រើន រៀនបានជ្រៅជ្រះ ទី២- **សិប្បៈ** មានជំនាញច្បាស់ ទី៣-**វិនយោ សុសិក្ខិតោ** មានវិន័យក្នុងកិច្ចការ ទី៤- **សុភាសិតាវាចា** ចេះនិយាយ និយាយត្រឹមត្រូវ។ មុំចង្ក្រានជីវិតមានបីគឺ ទី១-ត្រូវមានសុខភាពល្អ ទី២-ត្រូវមានចំណេះជំនាញ និងទី៣-ត្រូវមានគុណធម៌។ មនុស្សយើងត្រូវរៀនទម្លាក់ចោលនូវរឿងណាដែលមិនសំខាន់និងរឿងណាដែលធ្វើឱ្យយើងមិនសប្បាយចិត្ត។

លោកជំទាវបណ្ឌិត **ឃួន វិច្ឆិកា** បានសួរទៅព្រះតេជគុណ វិធីទម្លាក់ តើត្រូវធ្វើការទម្លាក់ដូចម្តេច? ព្រះតេជគុណបង្ហាញថា ដើម្បីទម្លាក់បានមនុស្សត្រូវមានសតិ និងបញ្ញា។









ជាកិច្ចបន្ទាប់បទអន្តរាគមន៍របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** *ស្តីពី«ការកែលម្អវិធីសាស្ត្របង្រៀនភាសាខ្មែរ ដើម្បីលើកកម្ពស់អំណាននៅកម្ពុជា»*

**ឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** បានលើកឡើងចំនួន៦ចំណុចមកបង្ហាញដូចខាងក្រោម៖

**១- សេចក្តីផ្តើម**

- **សង្គ្រាមអក្សរសាស្ត្រ** នៅឆ្នាំ១៩៨៥ ក្រសួងអប់រំបានបោះពុម្ពផ្សាយសៀវភៅ មានចំណងជើងថា «បញ្ហាទំនាញសូរក្នុងសំណេរ» ការអនុម័តលើគោលការណ៍ទំនាញសូរបានធ្វើឱ្យសង្គ្រាមអក្សរសាស្ត្រផ្ទុះឡើង ដោយមិនទាន់ឯកភាពក្នុងការសរសេរជាព្យាង្គរាយ និងព្យាង្គតម្រួត។ នៅឆ្នាំ១៩៩០ ការសរសេរតាមអាន និងតែងសេចក្តីបានលុបចេញពីកម្មវិធីសិក្សាគ្រប់ភូមិសិក្សា នៅឆ្នាំ២០០០ ជម្លោះអក្សរសាស្ត្រត្រូវបានបញ្ចប់ ដោយរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចគោរពប្រតិបត្តិតាមក្បួនច្បាប់នៃការសរសេរ និងអក្ខរាវិរុទ្ធ នៅក្នុងវចនានុក្រមខ្មែរ និពន្ធនិងចងក្រង ដោយ **សម្តេចព្រះសង្ឃរាជ ជួន ណាត**។
- **ការផ្លាស់ប្តូរវិធីសាស្ត្របង្រៀន** នៅឆ្នាំ១៩៩០ ក្រសួងអនុម័តឱ្យប្រើប្រាស់ វិធីសាស្ត្របង្រៀនតាមបែបសរុប សម្រាប់បង្រៀនអំណាននៅថ្នាក់ដំបូង។ នៅឆ្នាំ២០១០ មានការសិក្សាពីអ្នកជំនាញនៃក្រសួងអប់រំ និង Dr. Helen Abadzi អ្នកជំនាញជាន់ខ្ពស់របស់ធនាគារពិភពលោកបានធ្វើការសិក្សាស្រាវជ្រាវលើសិស្សចំនួន២៤០០នាក់ រៀននៅថ្នាក់ទី១ដល់ទី៦ ក្នុងស្រុកចំនួន៣៨ នៃខេត្តចំនួន១៨ ដោយទទួលឃើញថា ការរៀនតាមបែបវិធីសាស្ត្រប្រកប ទទួលបានលទ្ធផល ៣៩ភាគរយនៅឆ្នាំ២០១០ និង ៦៥ភាគរយ នៅឆ្នាំ២០១២។ ដូច្នេះនៅឆ្នាំ២០១២ ក្រសួងអប់រំ បានអនុម័ត វិធីសាស្ត្របង្រៀនតាមបែបស្គាល់សូរ ឬ វិធីសំយោគ ឬវិធីសាស្ត្របង្រៀនចៃត្រ ឆៃម។
- **វិធានការលើកកម្ពស់អក្ខរកម្ម** នៅឆ្នាំ២០១៤ ក្រសួងអប់រំ យុវជន និងកីឡា សម្រេចដាក់ឱ្យអនុវត្តឡើងវិញការសរសេរតាមអាន និងតែងសេចក្តី នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ។ នៅឆ្នាំ២០១៥ ក្រសួងបានរៀបចំបង្កើតពានរង្វាន់ «**សម្តេចតេជោសែន**» ដើម្បីជូននាយកល្អ និងគ្រូបង្រៀនល្អ។ ឆ្នាំ២០១៦ ក្រសួងបានត្រួតពិនិត្យការអនុវត្តអំណានដំបូងសាកល្បង ដោយមានការចូលរួមពីអង្គការដៃគូអភិវឌ្ឍន៍នានា ប៉ុន្តែនូវមិនទាន់មានការឯកភាពគ្នាទាំងស្រុងនូវឡើយ។ នៅឆ្នាំ២០១៨ ក្រសួងបានសហការជាមួយ RTI ដែលគាំទ្រដោយ USAID ដើម្បីអភិវឌ្ឍកញ្ចប់សម្ភារៈអំណានថ្នាក់ទី១។

**២- ទ្រឹស្តីនៃការរៀនភាសា**

- **ការចាប់យកភាសា** គឺដំណើរការទទួលយកភាសា ដោយមិនបានដឹងខ្លួន តាមរយៈការទំនាក់ទំនងជាមួយភាសា។ ការចាប់យកភាសា កើតឡើងដូចជាការរៀនភាសាកំណើតកុមារផ្តោតអារម្មណ៍លើការយល់សារ ពាក្យសម្តី និងការអនុវត្តជាក់ស្តែង។

- **ការរៀនភាសា** គឺជាការរៀនភាសានៅក្នុងថ្នាក់រៀន តាមមេរៀនដែលគ្រូបង្រៀន។

- **ទ្រឹស្តីពីធាតុចូលគ្រប់ជ្រុងជ្រោយ** បង្កើតឡើងដោយលោក Krashens ដើម្បីចេះភាសា អ្នកសិក្សាត្រូវទទួលធាតុចូលជាភាសា ដើម្បីបង្កើនកម្រិតស្ទាត់ជំនាញឱ្យកាន់តែខ្លាំងឡើងថែមទៀត ដូចជាពាក្យ វេយ្យាករណ៍ ការបន្លឺសំឡេង និងបរិបទសង្គម និងវប្បធម៌នៃការប្រើប្រាស់វាក្យសព្ទ។ ធាតុចូលគ្រប់ជ្រុងជ្រោយមានដូចជា៖ ១-អត្ថបទអំណាន ២-ការហាត់ស្តាប់ ៣-ការនិយាយ ៤-ការហាត់សរសេរ ៥-វេយ្យាករណ៍។ ម្យ៉ាងទៀតបណ្ណាល័យត្រូវរៀបចំឱ្យមានសៀវភៅ៦កម្រិតសម្រាប់សិស្សអាន។

## ៣- វិធីសាស្ត្របង្រៀនភាសាខ្មែរ

- វិធីសាស្ត្របង្រៀនតាមបែបស្គាល់សូរ ឬវិធីសំយោគ រៀនឱ្យស្គាល់សូរ ស្គាល់តួអក្សរ រៀនប្រកបអក្សរ ចេះវាក្យសព្ទ យល់ន័យពាក្យថ្មី ការចេះអានអត្ថបទ និងចេះសរសេរឈ្មោះ។

- វិធីសាស្ត្របង្រៀនតាមបែបសរុប គឺកុមារមើលឃើញរូបទាំងមូល ដោយការទន្ទេញពាក្យឱ្យចាំរត់មាត់ និងការភ្ជាប់ពាក្យជាមួយរូបភាព។

## ៤- វិធីសាស្ត្របង្រៀនថ្មីផ្តោតលើវិធីសាស្ត្រចម្រុះ

ដើម្បីឱ្យកុមារឆាប់ចេះអាននិងសរសេរ ចាំបាច់ត្រូវរៀនតាមលំដាប់លំដោយ តាមសមាសភាគទាំង៥នៃអំណាន រួមទាំងសំណេរមាន ១-ការស្គាល់សូរ ២-ការស្គាល់តួអក្សរនិងសូរ ៣-ការចេះវាក្យសព្ទ ៤-ការអានស្ទាត់ ៥-ការអានយល់ន័យ។

- គោលការណ៍បង្រៀន (ខ្ញុំធ្វើ យើងធ្វើ អ្នកធ្វើ) គឺជាគោលការណ៍បង្រៀន និងរៀនដ៏សំខាន់ដែលជានាំនូវការចូលរួមរបស់សិស្សក្នុងសកម្មភាពរៀនប្រកបដោយទំនុកចិត្ត និងមោទនភាព។
- វិធីសាស្ត្របង្រៀនចម្រុះ (ចាប់ផ្តើមពីវិធីស្គាល់សូរ និងបញ្ចប់តាមវិធីសរុប) គឺជាការច្របាច់បញ្ចូលគ្នានូវវិធីសាស្ត្រទាំងពីរ គឺការស្គាល់សូរអក្សរថ្មី ការស្គាល់តួអក្សរថ្មី ការអានព្យាង្គនិងពាក្យ វាក្យសព្ទ ការអានឈ្មោះ ការអានអត្ថបទថ្មីៗ និងការសរសេរ។

## ៥- វិធីសាស្ត្រអំណានក្នុងបណ្ណាល័យ

- អំណានក្នុងបណ្ណាល័យដើម្បីបណ្តុះទម្លាប់អាន គឺការបណ្តុះបំណិនអានឱ្យមានបំណិនអាន ការបណ្តុះទម្លាប់អានឱ្យមានទម្លាប់អាន។ អំណានក្នុងបណ្ណាល័យមានបួនគឺ ១-អំណានឮ ២-អំណានចូលរួម ៣-អំណានដៃគូ ៤-អំណានបុគ្គល។ ដើម្បីអនុវត្តអំណានទាំង៤នេះបាន បណ្ណាល័យត្រូវមានសៀវភៅសម្រាប់សិស្សអានបន្ថែម៦កម្រិត សមស្របទៅតាមកម្រិតថ្នាក់នីមួយៗ និងត្រូវរៀបចំតាមលក្ខណៈបច្ចេកទេសត្រឹមត្រូវ។

**៦- សេចក្តីសន្និដ្ឋាន**

- ការពង្រឹងអំណានដំបូងនៅតាមសាលារៀន គឺត្រូវលើកកម្ពស់ភាពជាម្ចាស់ ពង្រឹងសមត្ថភាពស្ថាប័ន និងសមត្ថភាពបុគ្គល ការបណ្តុះបណ្តាលគ្រូ កំណែទម្រង់សាលារៀនគ្រូល្អ នាយកល្អ បណ្ណាល័យមានស្តង់ដា អនុវត្តវិធីសាស្ត្រអំណានក្នុងបណ្ណាល័យ ការវិភាជន៍ថវិកា អធិការកិច្ចល្អ ការវាយតម្លៃ និងថវិកាសមិទ្ធកម្ម។
- ការពង្រឹងគុណភាពនៃការបណ្តុះបណ្តាលគ្រូ គឺត្រូវពង្រឹងគុណភាពក្នុងការជ្រើសរើស និងការបណ្តុះបណ្តាលគ្រូ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ការស្រាវជ្រាវប្រតិបត្តិ ថវិកាសមិទ្ធកម្ម បណ្តាញគ្រូបង្រៀនល្អ ការអប់រំឌីជីថល ភាពជាដៃគូ និងលើកទឹកចិត្ត គ្រូបង្រៀនល្អ នាយកល្អ និងអ្នកឯកទេសល្អ។
- ការបណ្តុះបំណិនអាន និងទម្លាប់អាន
- លើកកម្ពស់ការចូលរួមរបស់មាតាបិតា
- វិធានការលើកកម្ពស់អក្ខរកម្មមាន៩ចំណុចគឺ ១-ការកែលម្អវិធីសាស្ត្របង្រៀន ២-ការបណ្តុះបណ្តាលគ្រូ ៣-កំណែទម្រង់សាលារៀន-បណ្ណាល័យស្តង់ដា ៤-ការអភិវឌ្ឍសមត្ថភាពគ្រប់ជ្រុងជ្រោយរបស់សិស្ស ៥-ការត្រួតពិនិត្យ វាយតម្លៃ និងអធិការកិច្ចជាប្រចាំ ៦-ការលើកទឹកចិត្ត (គ្រូល្អ នាយកល្អ អ្នកឯកទេសល្អ) ៧-ការចូលរួមរបស់មាតាបិតានិងអ្នកពាក់ព័ន្ធ ៨-ការរៀបចំទិវាជាតិអំណាន ៩-ការលើកកម្ពស់ការតែងនិពន្ធ។

លោកជំទាវបណ្ឌិត **ឃួន វិច្ឆិកា** បានជម្រាបសួរទៅ **ឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** តើឯកឧត្តមយល់យ៉ាងណា ចំពោះការវិវត្តយ៉ាងលឿននៃបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិតAI?

**ឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី** មានប្រសាសន៍ថា បញ្ញាសិប្បនិម្មិត(AI)៖ បញ្ញាសិប្បនិម្មិត(AI) បានជួយជាគំនិតច្រើនប៉ុន្តែមិនស្មើខួរក្បាលមនុស្សទេ ខួរក្បាលមនុស្សល្អជាង។ម្យ៉ាងទៀត បញ្ញាសិប្បនិម្មិត(AI) បង្កើតឡើងជាមូលដ្ឋានសរសេរជាភាសាអង់គ្លេស ប៉ុន្តែភាសាខ្មែរមិនល្អទេ អាចស្តាប់មិនយល់ព្រោះវាជាការបកប្រែ។ ក្នុងនោះដែរការប្រើប្រាស់បញ្ញាសិប្បនិម្មិត(AI) ទាមទារឱ្យមានអ្នកជំនាញច្បាស់លាស់ និងសមត្ថភាពក្នុងការប្រើប្រាស់ ដើម្បីទាញយកផលប្រយោជន៍ពី បញ្ញាសិប្បនិម្មិត(AI)។




**ឯកឧត្តមបណ្ឌិត ហ៊ាន សុខុម** ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ នៃរាជបណ្ឌិត្យសភាកម្ពុជា បានចែករំលែកពីគោលការណ៍ចម្បងនៃការអាន *«សារៈសំខាន់បំណិនមូលដ្ឋាន និងយុទ្ធសាស្ត្រ»* ជាដំបូង **ឯកឧត្តមបណ្ឌិត** បានលើកឡើងពីបទពិសោធនអំណានកាលពីកុមារភាព ការសិក្សានៅសាកលវិទ្យាល័យ និងការសិក្សានៅបរទេសផងដែរ។ ជាពិសេសអនុសាសន៍ល្អៗ ដែលទទួលបានពីសាស្ត្រាចារ្យបង្រៀននៅសាកលវិទ្យាល័យ ដើម្បីទទួលបានជោគជ័យក្នុងការសិក្សានៅកម្រិតឧត្តមសិក្សា។ លើសពីនេះ **ឯកឧត្តមបណ្ឌិត** បានបង្ហាញពី ១-អត្ថប្រយោជន៍នៃអំណាន ២-មូលហេតុមួយចំនួនដែលធ្វើឱ្យមនុស្សមិនចូលចិត្តអាន ៣-គោលបំណងនៃការអាន។ ការអានមានយុទ្ធសាស្ត្រ៣យ៉ាងគឺ ១-យុទ្ធសាស្ត្រមុនអាន ២-យុទ្ធសាស្ត្រកំពុងអាន ៣-យុទ្ធសាស្ត្រពេលអានរួច។ បំណិនមូលដ្ឋានអំពីភាសាមាន ១-ការយល់ដឹងអំពីសូរសព្ទ ២-មានភាពស្ទាត់ជំនាញ ៣-ចេះវាក្យសព្ទ ៤-ការយល់ពេញលេញ។ សម្មតិកម្មបានបង្ហាញថាការខ្វះការអាន ឬខ្វះបំណិនក្នុងការអានតាំងពីអាយុតិចគឺជាបច្ច័យមិនល្អនៅពេលអនាគត ដែលអាចបាត់បង់ចំណង់ចំណូលចិត្តអាន និងឈានទៅរកការបោះបង់ការសិក្សា។ ជាចុងក្រោយ **ឯកឧត្តមបណ្ឌិត** សង្ឃឹមថាការបង្ហាញជូននូវបទពិសោធខាងលើកនឹងជួយលើកទឹកចិត្តអ្នកអានគ្រប់រូប ក្នុងការលើកកម្ពស់អំណានឱ្យកាន់តែប្រសើរឡើង ដោយអានហើយអានទៀត អានពេញមួយជីវិត។





## វេទិកាសំណួរ-ចម្លើយ

**សំណួរទី១៖** បើសិនជាចាប់ផ្តើមរៀនធម៌តើគួរចាប់ផ្តើមរៀនពីចំណុចណា? តើធម៌ មានបែងចែកជា ធម៌កម្រិតបឋម ធម៌កម្រិតមធ្យម ធម៌កម្រិតខ្ពស់ដែរឬទេ?

**ចម្លើយ៖** ការអប់រំពីព្រះធម៌ត្រូវចាប់ផ្តើមពីតូចគឺសំខាន់ណាស់។ បើអាច លោកគ្រូ អ្នកគ្រូ អាចសូត្រ នមោតស បន្ទាប់មក សូត្រនមសិកា និងសមាធិ ដោយធ្វើជារៀងរាល់ថ្ងៃ។ សៀវភៅធម៌សព្វថ្ងៃ មិនទាន់មានគ្រប់កម្រិតនៅឡើយទេ មានសៀវភៅធម៌សម្រាប់កម្រិតអនុវិទ្យាល័យ និងវិទ្យាល័យ ដូចជាសៀវភៅមង្គលជីវិតនិយាយ ពីមង្គល៣៨ប្រការមាគ៌ាជីវិត និយាយពីហេតុនាំឱ្យជីវិតវិនាស សីលធម៌ពុទ្ធសាសនា ។

**សំណួរទី២៖** តើក្រសួងអាចពង្រឹងទៅលើអំណាននៃអត្ថបទភាសាខ្មែរចាស់ និងអំណាននៃអត្ថបទភាសាខ្មែរកណ្តាល ដែលមានសារៈសំខាន់យ៉ាងដូចម្តេចខ្លះចំពោះការបង្កើតពាក្យថ្មី?

**ចម្លើយ៖** ការរៀនភាសាខ្មែរនៅក្នុងកម្មវិធីសិក្សាមិនអាចបង្រៀនភាសាខ្មែរចាស់ និងខ្មែរកណ្តាលបានទេ ព្រោះបច្ចុប្បន្នភាសានេះមានភាពស្មុគស្មាញដែលឈរលើមូលដ្ឋានភាសាសំស្ក្រឹតម្យ៉ាងទៀតពុំមានអ្នកប្រើប្រាស់ក្នុងបច្ចុប្បន្នទេ។ ការរៀនភាសាខ្មែរត្រូវរៀនតាមលំដាប់លំដោយតាមកម្មវិធីសិក្សាបច្ចុប្បន្ន ចំពោះអ្នកចង់រៀនខ្មែរចាស់ ឬខ្មែរកណ្តាល នៅថ្នាក់ឧត្តមសិក្សា ត្រូវយកឯកទេសអក្សរសាស្ត្រខ្មែរ ដែលទាមទារឱ្យមានការវិនិយោគ និងមនុស្សដើម្បីរៀន។

**សំណួរទី៣៖** ហេតុអ្វីបានជាក្រសួងអប់រំសរសេរ បន្ថែម ស្រៈ ◌េះ ◌ោះ ◌ិះ ◌ុះ តើមានបញ្ហាយ៉ាងណាដែលបង្កើតសញ្ញាស្រៈនេះ? ក្រសួងអប់រំគួរតែបង្កើតឱ្យមានស្តង់ដា និងការកែប្រព័ន្ធអក្ខរាវិរុទ្ធ ដូចភាសាអង់គ្លេស។

**ចម្លើយ៖** ដោយការវិវត្តនៃភាសា ហើយភាសាខ្មែរគឺមានកម្ចីពីភាសាបាលី និងភាសាសំស្ក្រឹតមកសម្គាល់ពាក្យ។ ដូច្នេះភាសាខ្មែរយើង មិនអាចបង្កើតជាស្តង់ដាបានទេ។



## IV. សេចក្ដីសន្និដ្ឋាន

ការរៀបចំប្រារព្ធពិធីទិវាជាតិអំណានលើកទី៩ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ បានប្រព្រឹត្តទៅដោយរលូន តាមកម្មវិធីដែលបានគ្រោងទុក និងទទួលបានលទ្ធផលជាទីមោទនយ៉ាងក្រៃលែង ដោយកម្មវិធីនីមួយៗនៃទិវាជាតិអំណានលើកទី៩ មានភាពល្អប្រសើរ និងរីកចម្រើនជាងឆ្នាំកន្លងមកដូចជា ១-ការប្រឡងប្រជែងជ្រើសរើសបេក្ខជនជ័យលាភី អាន ស្មូត្រកំណាព្យ និងតែងនិពន្ធ មានការចូលរួមផុលផុសតាមបណ្ដារាជធានី ខេត្ត ២-ការប្រឡងប្រជែងផ្នែកបកស្រាយប្រធានបទមានបេក្ខជន ចំនួន១២១អង្គ/នាក់ ៣-ប្រធានបទនៃបាឋកថាស្រាវជ្រាវ ៤-វេទិកាពិភាក្សាតុមូល កាន់តែមានខ្លឹមសារឆ្លើយតបនឹងតម្រូវការក្នុងពេលបច្ចុប្បន្ន ៥-ការចូលរួមពីលោកគ្រូ អ្នកគ្រូ និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងកម្មវិធីនីមួយៗនៃការប្រារព្ធពិធីមានបរិមាណកាន់តែច្រើនឡើងៗ។ ការរៀបចំស្តង់តាំងពិព័រណ៍សៀវភៅមាន១០៦ស្តង់ និងមាន៥៦ស្ថាប័ន រយៈពេល៣ថ្ងៃ មានអ្នកចូលរួមប្រមាណ៦៦០០០នាក់។ ការឃើញពីវឌ្ឍនភាពសៀវភៅ និងស្នាដៃរបស់អ្នកនិពន្ធ ការបណ្តុះគំនិតកុមារឱ្យចាប់អារម្មណ៍និងចូលចិត្តសៀវភៅ ជាពិសេសគឺការជាវសៀវភៅតាមចំណង់ចំណូលចិត្ត និងតាមតម្រូវការជាក់ស្តែងរបស់ពួកគាត់។

